ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាខាខេត្តស្ទឹងត្រែង

លេខ...៧២៤...ស...ក

ស្ទឹងត្រែង, ថ្ងៃទី២៤ ខែ ធ្នូ ឆ្នាំ២០១៤

អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង

ជម្រាបជូន

លោកអភិបាលនៃគណៈអភិបាលក្រុង ស្រុក

កម្មវត្ថុ ÷ ស្តីពីការរៀបចំសិក្ខាសាលាសមាហរណកម្មផែនការ ឃុំ សង្កាត់ នៅថ្នាក់ក្រុង ស្រុក។

យោង ÷ ប្រកាសអន្តរក្រសួងស្តីពី ការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងផែនការ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកអភិបាលនៃគណៈអភិបាលក្រុង ស្រុកទាំងអស់ជ្រាបថា៖ មន្ទីរផែនការខេត្តនឹងចុះរៀបចំសិក្ខាសាលាសមាហរណកម្មផែនការឃុំ សង្កាត់ នៅថ្នាក់ក្រុង ស្រុក តាមកាលបរិច្ឆេទ និងទីកន្លែងដូចខាងក្រោម៖

ល.រ	ក្រុង/ស្រុក	កាលបរិច្ឆេទ	ទីតាំង	គណៈអធិបតី
១	ក្រុងស្ទឹងត្រែង	០៨ ធ្នូ ២០១៤	សាលាក្រុងស្ទឹងត្រែង	ឯ.ឧ **កុល សំអុល**, ក្រុមប្រឹក្សា និងគណៈអភិបាលក្រុង
២	ស្រុកសៀមបូក	០៩ ធ្នូ ២០១៤	សាលាស្រុកសៀមបូក	ឯ.ឧ **ឈាង ឡាក់**, ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក
៣	ស្រុកសេសាន	១១ ធ្នូ ២០១៤	សាលាស្រុកសេសាន	លោកជំទាវ **គង់ ស៊ីផា**, ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក
៤	ស្រុកថាឡាបរិវ៉ាត់	១២ ធ្នូ ២០១៤	សាលាស្រុកថាឡាបរិវ៉ាត់	ឯ.ឧ **ម៉ុម សារឿន**, ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក
៥	ស្រុកសៀមប៉ាង	១៥ ធ្នូ ២០១៤	សាលាស្រុកសៀមប៉ាង	ឯ.ឧ **ដួង ពៅ**, ក្រុមប្រឹក្សា និងគណៈអភិបាលស្រុក

ដើម្បីបង្កើនការគាំទ្រ និងឆ្លើយតបសំណើជាអាទិភាពរបស់ឃុំ សង្កាត់ ព្រមទាំងធ្វើឱ្យសិក្ខាសាលាសមាហរណកម្មផែនការឃុំ សង្កាត់ នៅថ្នាក់ក្រុង ស្រុកនេះប្រព្រឹត្តិទៅដោយជោគជ័យ ខ្ញុំសូមដាក់ចេញនូវការងារសំខាន់ៗដូចខាងក្រោម៖

- អភិបាលក្រុង ស្រុក ត្រូវរៀបចំលិខិតអញ្ជើញគ្រប់មន្ទីរអង្គភាពដៃគូអភិវឌ្ឍន៍ និងក្រុមហ៊ុនដែលពាក់ព័ន្ធទាំងអស់នៅក្នុងក្រុង ស្រុក ឱ្យចូលរួម និងរៀបចំទីកន្លែងឱ្យបានសមស្រប ព្រមទាំងអញ្ជើញប្រធានក្រុមប្រឹក្សាក្រុង ស្រុក ចូលរួមជាគណៈអធិបតី។

- នាយកទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត ត្រូវចាត់មន្ត្រីក្រោមឱវាទឱ្យចុះជួយឃុំ សង្កាត់ ក្នុងការរៀបចំតាំងបង្ហាញគម្រោងអាទិភាព និងបង្ហាញពីរបាយការណ៍វឹកចម្រើននៃការអនុវត្តកិច្ចព្រមព្រៀងបណ្តោះអាសន្ន នាឆ្នាំកន្លងមក។
- មេឃុំ ចៅសង្កាត់ត្រូវចូលរួម និងចាត់អញ្ជើញជិទប់ឃុំ ចៅសង្កាត់រង អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ព្រមទាំងស្មៀនឃុំ សង្កាត់ឱ្យចូលរួមផងដែរ។

អាស្រ័យហេតុនេះសូមលោកអភិបាលនៃគណៈអភិបាលក្រុង ស្រុកជួយសម្របសម្រួលចាត់ចែង និងចូលរួមក្នុងសិក្ខាសាលាសមាហរណកម្មផែនការឃុំ សង្កាត់ នៅថ្នាក់ក្រុង ស្រុក ដ៏មានសារៈសំខាន់នេះ ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍមូលដ្ឋាន និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋឱ្យទទួលបានលទ្ធផលជោគជ័យ។

សូមលោក អភិបាលនៃគណៈអភិបាលក្រុង ស្រុកទទួលនូវសេចក្តីរាប់អានអំពីខ្ញុំ។

ចម្លងជូន៖

- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ក្រុមប្រឹក្សាខេត្ត

"ដើម្បីគោរពជូនជ្រាប"

- ក្រុមប្រឹក្សាក្រុង ស្រុក
- មន្ទីរអង្គភាពជុំវិញខេត្ត
- គ្រប់ទីចាត់ការ និងអង្គភាពចំណុះសាលាខេត្ត
- សាលាឃុំ សង្កាត់
- អង្គការជាតិ អន្តរជាតិ

"ដើម្បីសហការអនុវត្ត និងចូលរួមគាំទ្រ"

- ឯកសារកាលប្បវត្តិ